# សិលាចារឹកប្រាសាទប្រាប់ទិស ឬប្រាសាទកំពង់ក្ដី K.១៧១

ប្រាសាទប្រាប់ទិស ឬប្រាសាទកំពង់ក្ដី ស្ថិតនៅក្នុងភូមិប្រាសាទ ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប។ ប្រាសាទនេះស្ថិតនៅចម្ងាយប្រមាណជា៧០០ម៉ែត្រ នៃទិសអាគ្នេយ៍ស្ពានប្រាប់ទិស ឬស្ពានកំពង់ក្ដី។[១] លោក ហ្ស៊ក សឺដែស សន្និដ្ឋានថាប្រាសាទនេះប្រហែលជាទីតាំងមន្ទីរពេទ្យ ឬអរោគ្យសាលាមួយ នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទេវទី៧។[២] ប្រាសាទនេះ មានតួប្រាង្គមួយរាងបួនជ្រុងស្មើ មានមណ្ឌបលយមកទិសខាងកើត។ មានហោត្រៃមួយធ្វើពីថ្មបាយក្រៀម ស្ថិតនៅទិសអាគ្នេយ៍របស់ប្រាង្គ មានច្រកចូលពីទិសខាងលិច កំពែងរាងចតុកោណកែងធ្វើពីថ្មបាយក្រៀម។[៣] នៅទីតាំងនេះ គេធ្លាប់រកឃើញសិលាចារឹកចំនួន៣ផ្ទាំង មានចុះលេខបញ្ជី K.១៧០ K.១៧១ និង K.៧៦៩។ សិលាចារឹកដែលយើងយកមកបង្ហាញនាពេលនេះ ជាសិលាចារឹក K.១៧១ ដែលចារនៅលើមេទ្វារខាងត្បូង នៃច្រកចូលឬគោបុរៈខាងលិច។

សិលាចារឹកនេះ សរសេរជាភាសាខ្មែរបុរាណ មានចំនួន៩បន្ទាត់ ចុះកាលបរិច្ឆេទនាមហាសករាជឆ្នាំ៨៩១ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៦៩ ស្ថិតនៅក្នុងរាជ្យព្រះបាទជ័យវម៌្មទេវទី៥(ជ័យវរ្ម័នទី៥)។ សិលាចារឹកនេះជាព្រះរាជសាសន៍ឬព្រះរាជបញ្ជារបស់ព្រះបាទជ័យវម៌្មទេវទី៥ ត្រាស់ដល់គម្ដែងអញព្រះគ្រូ អាចារ្យ និងគម្ដែងអញដទៃទៀតជាបណ្ឌិតឱ្យស្ដាប់របាយការណ៍ព្រះរាជបុណ្យនិងបុណ្យរបស់រាស្ត្រផង មានម្រតាញកុរុង-ន្ទ ដែលមានសទ្ធារួមគ្នាជាមួយលោញធេញ និងលោញលក្ក ជាម្ចាស់ដើមបុណ្យ បានថ្វាយទ្រព្យនានាដល់ប្រាសាទប្រាប់ទិសនេះ។ ដង្វាយទាំងនោះមានអ្នកបម្រើប្រុសស្រីចំនួន២៣នាក់។ ចូវៅទិ ស្ពោក ពពិល នូទឹក ខាលស្រាព ចូដាក់ទឹកលាងជើង ដែលសុទ្ធសឹងសាងពីប្រាក់។ ចុងក្រោយ ជារបាយឈ្មោះដីស្រែនិងចំនួនដីស្រែបីកន្ទែងដែលថ្វាយចំពោះប្រាសាទនេះ។

---

[១] https://cisark.mcfa.gov.kh/core/showsite.php?id=297

[២] Cœdès 1954: 165។

[៣] https://cisark.mcfa.gov.kh/core/showsite.php?id=297

អត្ថបទដោយៈ ហ៊ិន ឈុនតេង

## អត្ថបទបុរាណជាអក្សរខ្មែរទំនើប

១- ០៨៩១នុមានិវ្រះគាសនធុលិវ្រះបាទធុលិជេង៉[៤]វ្រះកំម្រតេង៉អញ៑តកំ

២- ម្រតេង៉អញ៑វ្រះគុរុនុអាចាយ៌្យកំម្រតេង៉អញ៑[[ត]]បណ្ឌិត្តតិប្រេស្ដបិវត៌មាន[៥]វ្រះរាជ

៣- បុន្យនុបុណ្យរាម្រ្ដតមានិ(ផោង៉)ម្រតាញ៑កុរុង៉-ន្ទសមថ៌នុលោញ៑ធេយ៑នុលោញ៑ លក្ខគិនក្កនៃ

៤- [យបុ]ន្យនេះគិទ្រវ្យតិជ្វនិតវ្រះកំម្រតេង៉អញ៑ • ខ្ញុំ[៦]សីកន្ទេង៉តៃសំអបិតៃកំវ្រៀតៃ ជម្ន៌

៥- សិ[-ៃ◌]កនិស្រេចិ • សិកនិឥសិកនិហិសិកនិទ្រិសិនវ[៧]សិកំវិនិតៃកំវៃតៃកំវិតិតៃ ចាម្បតៃថ្ប្ស

៦- កិតៃសំឱយ៑សិបំនង៉សិកនិទិកិតៃបនិលសិតៃថ្ប្សកិតៃប-និ[៨]សិទីគ៌សិ(ប្រវាតិ)តៃ កនិ(តំៃ)

៧- តៃកនិស • វៅទិម្វាយស្វោកិម្វោយវលិវ្យលិវ្យរប្រោកិន្ទុ[៩]ទិកិម្វាយ៑ខាលិគរាវ្យរ អយ៌្យ

៨- បាទ្យម្វាយ៑តំបរនេះ(សិង៑)ប្រាក • អាយ៑ត្រវាង៉បកិស្រេជេង៉ម្វាយ៑អាយ៑វលធរ ស្រេជេង៉បិ

៩- យស្រេជេង៉--លិជេង៉អាយ៑វ្រះបយ៌្យង៉ស្រេត្រវាង៉ក្រ្វចិ០

---

[៤] លោក Cœdès (1954) អានជា៖ ធូលិវ្រះបាទធូលិជេង៉។

[៥] លោក Cœdès (1954) អានជា៖ ពត៌មាន។

[៦] លោក Cœdès (1954) អានជា៖ ក្ញុំ។

[៧] លោក Cœdès (1954) អានជា៖ នា។

[៨] លោក Cœdès (1954) អានជា៖ បណ្ឌ (paṇḍa)។

[៩] លោក Cœdès (1954) អានជា៖ ន្ទូ។ ពាក្យត្រឹមត្រូវជា «ន្ទូ»។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង៉

## អត្ថបទប្រែសម្រួលជាភាសាខ្មែរទំនើប

មហាសករាជឆ្នាំ៩៨១ មានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះកម្តែងអញ (ស្រីជ័យវម៌្មទេវទី៥)ដល់កម្តែងអញព្រះគ្រូ និងអាចារ្យ (និង)កម្តែងអញ (ជា)បណ្ឌិត ប្រើស្តាប់ព័ត៌មាន(/របាយការណ៍)ព្រះរាជបុណ្យនិងបុណ្យរបស់រាស្ត្រដែលមានផង។

ម្រតាញកុរុង-ន្ទ រួមជាមួយនិងលោញធេយ លោញលក្ក គឺអ្នកម្ចាស់បុណ្យ។ នេះគឺទ្រព្យដែលថ្វាយចំពោះ(ប្រាសាទ)ព្រះកម្តែងអញ។ ខ្ញុំបម្រើ សីកន្ទែង តៃសំអប់ តៃកំព្រៅ តៃធម៌ សី--កន្ទ្រាប់ សីកន្និន សិកន្និ សីកន្ទ្រិ សីនរ សីកំវិន តៃកំវៃ តៃកំវិត តៃចាម្ប តៃថ្មៀក តៃសម្អុយ សីបំណាង សិកន្និក តៃបន្ទាស់ តៃថ្មៀក តៃប-ន សីទីយ៌ សិប្រវាត តៃកន្តើម។ ថូវៅទិមួយ ស្តោកមួយ ពពិលប្រាក់ពីរ នូទឹកមួយ ខាលស្រាពពីរ ថូ/ចានដាក់ទឹកលាងជើងភ្ញៀវ៤។ (របស់ទាំង)នេះសុទ្ធសឹងសាងពីប្រាក់។ នៅឯត្រពាំងបក់ ស្រែចំនួនមួយជើង នៅឯវលធរស្រែបីជើង ស្រែជើង---ជើង នៅឯព្រះប្រេង(គឺ)ស្រែត្រពាំងក្រួច៕

## វាក្យសព្ទសំខាន់ៗ

| | |
|---|---|
| វ្រះគាសន | ព្រះរាជសាសន៍ ព្រះរាជតម្រាស់ ព្រះរាជបញ្ជា។ |
| វត៌មាន | ព័ត៌មាន ដំណឹង របាយការណ៍។ (វ > ព) |
| សមថ៌ | (សំ. < សំ = រួមគ្នា + អថ៌ = ប្រយោជន៍) គំនិតរួមគ្នា បំណងដូចគ្នា ចូលរួមជាមួយគ្នា |
| សី/សិ | ឋានន្តរនាមសម្គាល់អ្នកបម្រើប្រុស។ |
| តៃ | ឋានន្តរនាមសម្គាល់អ្នកបម្រើស្រី។ |
| វៅទិ | (សំ.) ថូម្យ៉ាងធ្វើពីលោហៈ។ ពាក្យនេះក្លាយមកជា «ប៉ោត»។ |
| វលិវ្យលិ | ពពិល។ (វ > ព) |
| ខាលិគរាវ | ផ្តិល(ខាត់?)មានជើងស្រាពក៏។ |
| អឃ៌្យបាទ្យ | (សំ.) ថូដាក់ទឹកលាងជើងភ្ញៀវ។ |

អត្ថបទដោយៈ ហ៊ិន ឈុនតេង

# ឯកសារយោង

Cœdès, G.

1927. *Inscriptions du Cambodge (vol. 6)*. Paris

CISARK

https://cisark.mcfa.gov.kh/core/showsite.php?id=297

## បញ្ជីរូបភាព



ប្រាសាទប្រាប់ទិស (រូបថត៖ Bruno & Cisark)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



ស្រះទឹកមានរៀបថ្មបាយក្រៀម (រូបថត៖ Bruno & Cisark)



សំណៅផ្តិតសិលាចារឹក K.១៧១ (រូបថត៖ EFEO & Cisark)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង